**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**
**Kingdom of Cambodia**
**Nation Religion King**

**ក្រសួងរ៉ែ និងថាមពល**
**Ministry of Mines and Energy**
**លេខៈ** ០២៧៣ រ៉ែ.រថ.បគអថ.ប្រក

# ប្រកាស
# ស្តីពី
# ការដាក់ឱ្យអនុវត្តផែនការបញ្ជីថ្លៃលក់អគ្គិសនីសម្រាប់ឆ្នាំ ២០២៥

## រដ្ឋមន្ត្រីក្រសួងរ៉ែ និងថាមពល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៣/០១៧ ចុះថ្ងៃទី៩ ខែធ្នូ ឆ្នាំ២០១៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរ៉ែ និងថាមពល
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៩៧ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ និងព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/២០៤៤ ចុះថ្ងៃទី២៦ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងមុខតំណែងឥស្សរជនជារដ្ឋលេខាធិការ និងអនុរដ្ឋលេខាធិការនៃក្រសួងរ៉ែ និងថាមពល
- បានឃើញអនុក្រឹត្យលេខ១៣៧ អនក្រ.បក ចុះថ្ងៃទី៣១ ខែតុលា ឆ្នាំ២០១៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃក្រសួងរ៉ែ និងថាមពល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០២០១/០៣ ចុះថ្ងៃទី០២ ខែកុម្ភៈ ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីអគ្គិសនីនៃព្រះរាជាណាចក្រកម្ពុជា
- យោងប្រកាសរបស់ក្រសួងរ៉ែ និងថាមពលលេខ០៤០៨ រថ.បគអថ.ប្រក ចុះថ្ងៃទី១២ ខែធ្នូ ឆ្នាំ២០២៣ ស្តីពីការដាក់ឱ្យអនុវត្តផែនការបញ្ជីថ្លៃលក់អគ្គិសនីសម្រាប់ឆ្នាំ ២០២៤
- យោងកិច្ចប្រជុំរវាងក្រសួងរ៉ែ និងថាមពល អាជ្ញាធរអគ្គិសនីកម្ពុជា និងអគ្គិសនីកម្ពុជា ពិភាក្សាអំពីផែនការកំណត់បញ្ជីថ្លៃលក់អគ្គិសនីឆ្នាំ២០២៥ នៅថ្ងៃទី១១ ខែកញ្ញា ឆ្នាំ២០២៤
- យោងការចាំបាច់របស់ក្រសួងរ៉ែ និងថាមពល។

# សម្រេច

**ប្រការ ១.-**

ដាក់ចេញនូវ "ផែនការបញ្ចីថ្លៃលក់អគ្គិសនីសម្រាប់ឆ្នាំ២០២៥" សម្រាប់ការផ្គត់ផ្គង់អគ្គិសនីពីប្រព័ន្ធបណ្តាញជាតិនៅទូទាំងប្រទេស ដែលមានបង្ហាញនៅតារាងក្នុងប្រការជាបន្តបន្ទាប់ខាងក្រោម។

**ប្រការ ២.-**

"ផែនការបញ្ចីថ្លៃលក់អគ្គិសនីសម្រាប់ឆ្នាំ ២០២៥" ដែលបានដាក់ចេញក្នុងប្រការ ១ ខាងលើ មានអត្រាថ្លៃ និងរចនាសម្ព័ន្ធថ្លៃ ទៅតាមប្រភេទនៃអ្នកប្រើប្រាស់ និងទៅតាមលក្ខខណ្ឌទិញ ដូចកំណត់ក្នុងតារាងខាងក្រោម ៖

| ប្រភេទអ្នកប្រើប្រាស់ និងលក្ខខណ្ឌទិញ | ឯកតា | ផែនការថ្លៃអគ្គិសនី ឆ្នាំ២០២៥ |
|---|---|---|
| **១. អ្នកប្រើប្រាស់ភ្ជាប់ពីទ្វារចរន្តតង់ស្យុងខ្ពស់អនុស្ថានីយ៖** | | |
| ➢ ជម្រើសបង់ថ្លៃអគ្គិសនីតាមអត្រាថ្លៃមធ្យម | $/kWh | 0.1170 |
| ➢ ជម្រើសបង់ថ្លៃអគ្គិសនីតាមពេលវេលា និងអានុភាព | | |
| ១. អត្រាថ្លៃប្រើប្រាស់អានុភាព | $/kW/ខែ | 2.00 |
| ២. អត្រាថ្លៃប្រើប្រាស់ថាមពលក្នុងពេលមានបន្ទុកច្រើន (៧ព្រឹកដល់៩យប់) | $/kWh | 0.1140 |
| ៣. អត្រាថ្លៃប្រើប្រាស់ថាមពលក្នុងពេលមានបន្ទុកតិច (៩យប់ដល់៧ព្រឹក) | $/kWh | 0.0940 |
| **២. អ្នកប្រើប្រាស់ប្រភេទពាណិជ្ជកម្ម ភ្ជាប់ពីទ្វារចរន្តតង់ស្យុងមធ្យមនៃអនុស្ថានីយក្នុង និងក្រៅក្រុងភ្នំពេញ និងតាខ្មៅ ៖** | | |
| ➢ ជម្រើសបង់ថ្លៃអគ្គិសនីតាមអត្រាថ្លៃមធ្យម | $/kWh | 0.1320 |
| ➢ ជម្រើសបង់ថ្លៃអគ្គិសនីតាមពេលវេលា និងអានុភាព | | |
| ១. អត្រាថ្លៃប្រើប្រាស់អានុភាព | $/kW/ខែ | 2.50 |
| ២. អត្រាថ្លៃប្រើប្រាស់ថាមពលក្នុងពេលមានបន្ទុកច្រើន (៧ព្រឹកដល់៩យប់) | $/kWh | 0.1290 |
| ៣. អត្រាថ្លៃប្រើប្រាស់ថាមពលក្នុងពេលមានបន្ទុកតិច (៩យប់ដល់៧ព្រឹក) | $/kWh | 0.0960 |
| **៣. អ្នកប្រើប្រាស់ប្រភេទឧស្សាហកម្ម ភ្ជាប់ពីទ្វារចរន្តតង់ស្យុងមធ្យមនៃអនុស្ថានីយក្នុងក្រុងភ្នំពេញ និងតាខ្មៅ ៖** | | |
| ➢ ជម្រើសបង់ថ្លៃអគ្គិសនីតាមអត្រាថ្លៃមធ្យម | $/kWh | 0.1320 |
| ➢ ជម្រើសបង់ថ្លៃអគ្គិសនីតាមពេលវេលា និងអានុភាព | | |
| ១. អត្រាថ្លៃប្រើប្រាស់អានុភាព | $/kW/ខែ | 2.50 |
| ២. អត្រាថ្លៃប្រើប្រាស់ថាមពលក្នុងពេលមានបន្ទុកច្រើន (៧ព្រឹកដល់៩យប់) | $/kWh | 0.1180 |
| ៣. អត្រាថ្លៃប្រើប្រាស់ថាមពលក្នុងពេលមានបន្ទុកតិច (៩យប់ដល់៧ព្រឹក) | $/kWh | 0.0960 |
| **៤. អ្នកប្រើប្រាស់ប្រភេទឧស្សាហកម្ម ភ្ជាប់ពីទ្វារចរន្តតង់ស្យុងមធ្យមនៃអនុស្ថានីយក្រៅក្រុងភ្នំពេញ និងតាខ្មៅ ៖** | | |
| ➢ ជម្រើសបង់ថ្លៃអគ្គិសនីតាមអត្រាថ្លៃមធ្យម | $/kWh | 0.1210 |
| ➢ ជម្រើសបង់ថ្លៃអគ្គិសនីតាមពេលវេលា និងអានុភាព | | |
| ១. អត្រាថ្លៃប្រើប្រាស់អានុភាព | $/kW/ខែ | 2.50 |
| ២. អត្រាថ្លៃប្រើប្រាស់ថាមពលក្នុងពេលមានបន្ទុកច្រើន (៧ព្រឹកដល់៩យប់) | $/kWh | 0.1180 |
| ៣. អត្រាថ្លៃប្រើប្រាស់ថាមពលក្នុងពេលមានបន្ទុកតិច (៩យប់ដល់៧ព្រឹក) | $/kWh | 0.0960 |

| | | |
|---|---|---|
| **៥. អ្នកប្រើប្រាស់ឧស្សាហកម្ម និងកសិកម្ម ភ្ជាប់ពីខ្សែបណ្តាញតង់ស្យុងមធ្យម៖** * | | |
| ➢ ជម្រើសបង់ថ្លៃអគ្គិសនីតាមអត្រាថ្លៃមធ្យម | $/kWh | 0.1370 |
| ➢ ជម្រើសបង់ថ្លៃអគ្គិសនីតាមពេលវេលា និងអានុភាព | | |
| ១. អត្រាថ្លៃប្រើប្រាស់អានុភាព | $/kW/ខែ | 3.00 |
| ២. អត្រាថ្លៃប្រើប្រាស់ថាមពលក្នុងពេលមានបន្ទុកច្រើន (៧ព្រឹកដល់៩យប់) | $/kWh | 0.1300 |
| ៣. អត្រាថ្លៃប្រើប្រាស់ថាមពលក្នុងពេលមានបន្ទុកតិច (៩យប់ដល់៧ព្រឹក) | $/kWh | 0.1100 |
| **៦. អ្នកប្រើប្រាស់ប្រភេទពាណិជ្ជកម្ម រដ្ឋបាល និងផ្សេងៗ ភ្ជាប់ពីខ្សែបណ្តាញតង់ស្យុងមធ្យម ៖** * | | |
| ➢ ជម្រើសបង់ថ្លៃអគ្គិសនីតាមអត្រាថ្លៃមធ្យម | $/kWh | 0.1580 |
| ➢ ជម្រើសបង់ថ្លៃអគ្គិសនីតាមពេលវេលា និងអានុភាព | | |
| ១. អត្រាថ្លៃប្រើប្រាស់អានុភាព | $/kW/ខែ | 3.50 |
| ២. អត្រាថ្លៃប្រើប្រាស់ថាមពលក្នុងពេលមានបន្ទុកច្រើន (៧ព្រឹកដល់៩យប់) | $/kWh | 0.1500 |
| ៣. អត្រាថ្លៃប្រើប្រាស់ថាមពលក្នុងពេលមានបន្ទុកតិច (៩យប់ដល់៧ព្រឹក) | $/kWh | 0.1240 |
| ➢ ចំពោះអ្នកប្រើប្រាស់ប្រភេទរដ្ឋបាលសាធារណៈដែលទូទាត់ដោយថវិការដ្ឋ បង់ថ្លៃអគ្គិសនីតាមអត្រាថ្លៃមធ្យម | រៀល/kWh | 653 |
| **៧. អ្នកប្រើប្រាស់ឧស្សាហកម្ម និងកសិកម្ម ភ្ជាប់ពីក្រោមត្រង់ស្វូចែកចាយតាមកុងទ័រ LV (ត្រង់ស្វូផ្ទាល់ខ្លួន )៖** | | |
| ➢ ជម្រើសបង់ថ្លៃអគ្គិសនីតាមអត្រាថ្លៃមធ្យម | $/kWh | 0.14248 |
| ➢ ជម្រើសបង់ថ្លៃអគ្គិសនីតាមពេលវេលា និងអានុភាព | | |
| ១. អត្រាថ្លៃប្រើប្រាស់អានុភាព | $/kW/ខែ | 3.00 |
| ២. អត្រាថ្លៃប្រើប្រាស់ថាមពលក្នុងពេលមានបន្ទុកច្រើន (៧ព្រឹកដល់៩យប់) | $/kWh | 0.13520 |
| ៣. អត្រាថ្លៃប្រើប្រាស់ថាមពលក្នុងពេលមានបន្ទុកតិច (៩យប់ដល់៧ព្រឹក) | $/kWh | 0.11440 |
| **ចំពោះអ្នកសុំឱ្យអ្នកផ្គត់ផ្គង់វិនិយោគត្រង់ស្វូឱ្យខ្លួន ៖** | | |
| ➢ ជម្រើសបង់ថ្លៃអគ្គិសនីតាមអត្រាថ្លៃមធ្យម | $/kWh | 0.15048 |
| ➢ ជម្រើសបង់ថ្លៃអគ្គិសនីតាមពេលវេលា និងអានុភាព | | |
| ១. អត្រាថ្លៃប្រើប្រាស់អានុភាព | $/kW/ខែ | 3.00 |
| ២. អត្រាថ្លៃប្រើប្រាស់ថាមពលក្នុងពេលមានបន្ទុកច្រើន (៧ព្រឹកដល់៩យប់) | $/kWh | 0.14320 |
| ៣. អត្រាថ្លៃប្រើប្រាស់ថាមពលក្នុងពេលមានបន្ទុកតិច (៩យប់ដល់៧ព្រឹក) | $/kWh | 0.12240 |
| **៨. អ្នកប្រើប្រាស់ប្រភេទពាណិជ្ជកម្ម រដ្ឋបាល និងផ្សេងៗ ភ្ជាប់ពីក្រោមត្រង់ស្វូចែកចាយតាមកុងទ័រ LV (ត្រង់ស្វូផ្ទាល់ខ្លួន )៖** | | |
| ➢ ជម្រើសបង់ថ្លៃអគ្គិសនីតាមអត្រាថ្លៃមធ្យម | $/kWh | 0.16432 |
| ➢ ជម្រើសបង់ថ្លៃអគ្គិសនីតាមពេលវេលា និងអានុភាព | | |
| ១. អត្រាថ្លៃប្រើប្រាស់អានុភាព | $/kW/ខែ | 3.50 |
| ២. អត្រាថ្លៃប្រើប្រាស់ថាមពលក្នុងពេលមានបន្ទុកច្រើន (៧ព្រឹកដល់៩យប់) | $/kWh | 0.15600 |
| ៣. អត្រាថ្លៃប្រើប្រាស់ថាមពលក្នុងពេលមានបន្ទុកតិច (៩យប់ដល់៧ព្រឹក) | $/kWh | 0.12896 |
| ➢ ចំពោះអ្នកប្រើប្រាស់ប្រភេទរដ្ឋបាលសាធារណៈដែលទូទាត់ដោយថវិការដ្ឋ បង់ថ្លៃអគ្គិសនីតាមអត្រាថ្លៃមធ្យម | រៀល/kWh | 679 |
| **ចំពោះអ្នកសុំឱ្យអ្នកផ្គត់ផ្គង់វិនិយោគត្រង់ស្វូឱ្យខ្លួន ៖** | | |
| ➢ ជម្រើសបង់ថ្លៃអគ្គិសនីតាមអត្រាថ្លៃមធ្យម | $/kWh | 0.17232 |

| | | |
|---|---|---|
| ➢ ជម្រើសបង់ថ្លៃអគ្គិសនីតាមពេលវេលា និងអានុភាព<br>១. អត្រាថ្លៃប្រើប្រាស់អានុភាព<br>២. អត្រាថ្លៃប្រើប្រាស់ថាមពលក្នុងពេលមានបន្ទុកច្រើន (៧ព្រឹកដល់៩យប់)<br>៣. អត្រាថ្លៃប្រើប្រាស់ថាមពលក្នុងពេលមានបន្ទុកតិច (៩យប់ដល់៧ព្រឹក)<br>➢ ចំពោះអ្នកប្រើប្រាស់ប្រភេទរដ្ឋបាលសាធារណៈដែលទូទាត់ដោយថវិការដ្ឋ បង់ថ្លៃអគ្គិសនីតាមអត្រាថ្លៃមធ្យម | <br>$/kW/ខែ<br>$/kWh<br>$/kWh<br><br>រៀល/kWh | <br>3.50<br>0.16400<br>0.13696<br><br>712 |
| **៩. អ្នកប្រើប្រាស់ភ្ជាប់ពីខ្សែបណ្ដាញចែកចាយ LV ៖**<br>៩.១ អ្នកប្រើប្រាស់លំនៅដ្ឋាន ៖<br>➢ អ្នកប្រើពី ១ ដល់ ១០ គីឡូវ៉ាត់ម៉ោង ក្នុង១ខែ<br>➢ អ្នកប្រើពី ១១ ដល់ ៥០ គីឡូវ៉ាត់ម៉ោង ក្នុង១ខែ<br>➢ អ្នកប្រើពី ៥១ ដល់ ២០០ គីឡូវ៉ាត់ម៉ោង ក្នុង១ខែ<br>➢ អ្នកប្រើលើសពី ២០០ គីឡូវ៉ាត់ម៉ោង ក្នុង១ខែ<br>៩.២ អ្នកប្រើប្រាស់ប្រភេទផ្សេងទៀត ក្រៅពីលំនៅដ្ឋាន<br>៩.៣ សាលារៀន មន្ទីរពេទ្យ មណ្ឌលសុខភាព នៅជនបទ | <br><br>រៀល/kWh<br>រៀល/kWh<br>រៀល/kWh<br>រៀល/kWh<br>រៀល/kWh<br>រៀល/kWh | <br><br>380<br>480<br>610<br>730<br>730<br>610 |
| **១០. អ្នកបូមទឹកធ្វើកសិកម្ម និងអ្នកប្រើប្រាស់ក្នុងវិស័យកសិកម្ម ភ្ជាប់ពីខ្សែបណ្ដាញចែកចាយ MV និង LV ****<br>ប្រើប្រាស់នៅពេលយប់ ពីម៉ោង ៩យប់ ដល់ម៉ោង ៧ព្រឹក | <br>រៀល/kWh | <br>480 |

* អ្នកប្រើប្រាស់ធុនធំ គឺជាអ្នកប្រើប្រាស់ទាំងឡាយណាដែលត្រូវទទួលការផ្គត់ផ្គង់អគ្គិសនីតាមតង់ស្យុងមធ្យម និងមានអានុភាពចាប់ពី ២៧៥ គីឡូវ៉ាត់ឡើង ។ ក្នុងករណីនេះ នាឡិកាស្ទង់អាចតម្លើងនៅផ្នែក MV ឬ ផ្នែក LV ក្រោមត្រង់ស្វូ។

** គ្រប់ប្រភេទអ្នកប្រើប្រាស់ក្នុងវិស័យកសិកម្មទាំងអស់ដែលបានសុំប្រើប្រាស់ពេលយប់ មានថ្លៃ 480 រៀល/kWh និងថាមពលដែលបានប្រើប្រាស់ពេលថ្ងៃពីម៉ោង ៧ព្រឹក ដល់ម៉ោង ៩យប់ គិតតាមអត្រាថ្លៃមធ្យម តាមប្រភេទអ្នកប្រើប្រាស់កំណត់ខាងលើ ។

## ប្រការ ៣ ._

ចំពោះអ្នកប្រើប្រាស់មានដាក់តម្លើងប្រភពពន្លឺព្រះអាទិត្យ ដាក់ផែនការឱ្យអនុវត្តតាមការកំណត់នៅក្នុងបញ្ជីថ្លៃលក់អគ្គិសនីឆ្នាំ ២០២៣ ជាបណ្ដោះអាសន្នសិន រហូតដល់អាជ្ញាធរអគ្គិសនីកម្ពុជាធ្វើការកំណត់អត្រាថ្លៃប៉ះប៉ូវពីអ្នកប្រើប្រាស់ដែលមានប្រព័ន្ធថាមពលពន្លឺព្រះអាទិត្យក្នុងក្របខណ្ឌនៃ "គោលការណ៍សម្រាប់ការអនុញ្ញាតឱ្យប្រើប្រាស់ថាមពលពន្លឺព្រះអាទិត្យលើដំបូលនៅកម្ពុជា" ចេញដោយក្រសួងរ៉ែនិងថាមពល ជាផ្លូវការរួចរាល់ ទើបកំណត់ឱ្យអនុវត្តតាមអត្រាថ្លៃប៉ះប៉ូវពីអ្នកប្រើប្រាស់ដែលមានប្រព័ន្ធថាមពលពន្លឺព្រះអាទិត្យ ដែលអាជ្ញាធរអគ្គិសនីកម្ពុជាបានកំណត់។

## ប្រការ ៤ ._

ដើម្បីគាំទ្រការអនុវត្ត "ផែនការបញ្ជីថ្លៃលក់អគ្គិសនីសម្រាប់ឆ្នាំ ២០២៥" ដែលផ្គត់ផ្គង់ដោយអ្នកធ្វើសេវាកម្មផ្គត់ផ្គង់អគ្គិសនីឯកជន ទាំងបញ្ជូនរង និងទាំងចែកចាយ អត្រាថ្លៃសម្រាប់ការផ្គត់ផ្គង់ប្រភពអគ្គិសនីទៅឱ្យអ្នកផ្គត់ផ្គង់បន្ត (បញ្ជូនរងនិងចែកចាយ) ត្រូវអនុវត្ត ដូចការកំណត់ក្នុងតារាងខាងក្រោម ៖

| **ប្រភេទនៃការទិញរបស់អ្នកផ្គត់ផ្គង់បន្ត** | **ឯកតា** | **ផែនការថ្លៃអគ្គិសនី ឆ្នាំ ២០២៥** |
|---|---|---|
| ១.អ្នកផ្គត់ផ្គង់បន្តដែលទិញពីទ្វារចេន្ត MV នៃអនុស្ថានីយ | $/kWh | 0.1190 |

| | | |
|---|---|---|
| ២.អ្នកផ្គត់ផ្គង់បន្តដែលទិញពីខ្សែ MV តាមនាឡិកា MV | $/kWh | 0.1290 |
| ៣.អ្នកផ្គត់ផ្គង់បន្តដែលទិញក្រោមត្រង់ស្វូតាមនាឡិកា LV ៖ | | |
| 1. ករណីត្រង់ស្វូវិនិយោគដោយអ្នកទិញ | $/kWh | 0.13416 |
| 2. ករណីត្រង់ស្វូវិនិយោគដោយអ្នកលក់ | $/kWh | 0.14216 |

## ប្រការ ៥.-

"ផែនការបញ្ចីថ្លៃលក់អគ្គិសនីសម្រាប់ឆ្នាំ ២០២៥" ដែលបានដាក់ចេញក្នុងប្រកាសនេះ មានវិសាលភាពលើតំបន់ផ្គត់ផ្គង់អគ្គិសនីទាំងឡាយ ដែលយកប្រភពអគ្គិសនីពីបណ្ដាញជាតិ កំណត់ដោយអាជ្ញាធរអគ្គិសនីកម្ពុជា ទៅតាមស្ថានភាពនៃការអភិវឌ្ឍពង្រីកបណ្ដាញជាតិ លើកលែងតែតំបន់សេដ្ឋកិច្ចពិសេស ឬតំបន់ឧស្សាហកម្ម ដែលមិនស្ថិតនៅក្នុងយន្តការឧបត្ថម្ភធនរួម និងដែលអាស្រ័យទៅតាមទំហំនៃការវិនិយោគរៀបចំហេដ្ឋារចនាសម្ព័ន្ធផ្គត់ផ្គង់អគ្គិសនី និងដង់ស៊ីតេនៃការប្រើប្រាស់អគ្គិសនីដោយឡែក ព្រមទាំងការប្រើរោងចក្រអគ្គិសនីផ្ទាល់ខ្លួនបន្ថែមពីលើការយកប្រភពអគ្គិសនីពីបណ្ដាញជាតិរបស់អគ្គិសនីកម្ពុជា។ ពេលវេលា លក្ខខណ្ឌនៃការអនុវត្ត និងការកំណត់បញ្ចីថ្លៃលក់អគ្គិសនីជាក់ស្ដែង ការកំណត់ថ្លៃលក់អគ្គិសនីនៅក្នុងតំបន់សេដ្ឋកិច្ចពិសេស ឬតំបន់ឧស្សាហកម្ម និងការកំណត់អត្រាថ្លៃសម្រាប់លើកទឹកចិត្តដល់អ្នកប្រើប្រាស់ និងអ្នកផ្គត់ផ្គង់បន្ត ក្នុងការជួយយកប្រភពអគ្គិសនីក្នុងវេលាស្សាបន្ថែម ឬរដូវចុងឆ្នាំ និងដើមឆ្នាំ អាជ្ញាធរអគ្គិសនីកម្ពុជា អាចធ្វើការសម្រេចទៅតាមការកំណត់របស់ច្បាប់ស្ដីពីអគ្គិសនីនៃព្រះរាជាណាចក្រកម្ពុជា។

## ប្រការ ៦.-

អង្គភាព និងស្ថាប័នពាក់ព័ន្ធទាំងអស់ដែលរួមមាន អគ្គនាយកដ្ឋានថាមពល មន្ទីររ៉ែនិងថាមពល រាជធានី/ខេត្ត អាជ្ញាធរអគ្គិសនីកម្ពុជា មូលនិធិអគ្គិសនីភាវូបនីយកម្មជនបទ និងអ្នកកាន់អាជ្ញាបណ្ណធ្វើសេវាកម្មអគ្គិសនីគ្រប់ប្រភេទនៅក្នុងព្រះរាជាណាចក្រកម្ពុជា ត្រូវរួមគ្នាពិនិត្យលទ្ធភាពអនុវត្ត "ផែនការបញ្ចីថ្លៃលក់អគ្គិសនីសម្រាប់ឆ្នាំ២០២៥" ដែលបានដាក់ចេញនៅក្នុងប្រកាសនេះ ឱ្យអស់ពីលទ្ធភាព។

## ប្រការ ៧.-

ប្រកាស និងសេចក្ដីសម្រេចទាំងឡាយណា ដែលផ្ទុយនឹងប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍។

## ប្រការ ៨.-

ប្រកាសនេះ មានប្រសិទ្ធភាពអនុវត្ត សម្រាប់ខួបនៃបញ្ចីថ្លៃលក់ឆ្នាំ២០២៥ ។

ថ្ងៃសុក្រ ៨កើត ខែកត្តិក ឆ្នាំរោង ឆស័ក ព.ស.២៥៦៨

រាជធានីភ្នំពេញ ថ្ងៃទី ៨ ខែវិច្ឆិកា ឆ្នាំ២០២៤

**រដ្ឋមន្ត្រីក្រសួងរ៉ែ និងថាមពល**

**កែវ រតនៈ**

**ចម្លងជូន៖**
- ទីស្ដីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្ដេចធិបតី នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- គ្រប់ក្រសួង ស្ថាប័ន
- គ្រប់សាលារាជធានី ខេត្ត "ដើម្បីជូនជ្រាប"
- ដូចប្រការ ៦ "ដើម្បីអនុវត្ត"
- ឯកសារ-កាលប្បវត្តិ